

# មីនា ចង់ស្គាល់សមុទ្រ

Đỗ Giáp Nhất

Lê Thị Mai Phương

Let's Read

The Asia Foundation



ភូមិរបស់ខ្ញុំត្រូវបានគ្របដណ្តប់ដោយអ័ព្ទពណ៌សដ៏ត្រជាក់។ លោកគ្រូខ្ញុំនិយាយថា៖ «នៅក្នុងភូមិរបស់គ្រូ មានដីខ្សាច់ខ្មៅដូចជាធ្យូង។»



លោកគ្រូបានបង្រៀនអក្សរ និងលេខដល់ពួកយើង។ ពួកយើងមិនដឹងថាភូមិរបស់គាត់នៅទីណាឡើយ។ នៅពេលខ្ញុំសួរ គាត់បានឆ្លើយថា៖ «គ្រូមកពីភូមិមួយនៅជិតសមុទ្រ។»



ខ្ញុំក៏សួរគាត់បន្តៈ «តើភូមិលោកគ្រូនៅឯណា? តើសត្វក្របីនៅភូមិលោកគ្រូធំៗដែរទេ? តើសត្វជ្រូកនៅភូមិលោកគ្រូធាត់ៗដែរទេ?» លោកគ្រូក៏ឆ្លើយតបវិញថាៈ «សមុទ្រគ្មានសត្វក្របីធំៗ ឬសត្វជ្រូកធាត់ៗនោះទេ។ សមុទ្រមានត្រីច្រើនប្រភេទ និងមានពន្លឺព្រះអាទិត្យដ៏កក់ក្ដៅ។»



សមុទ្រដ៏កក់ក្ដៅ! ស្ដាប់ទៅគួរឱ្យចង់ទៅណាស់!
ខ្ញុំមិនចូលចិត្តភូមិខ្ញុំទេ។ មានតែអព្ទ័ ហើយអត់មានពន្លឺព្រះអាទិត្យទេ ។
ខ្ញុំប្រាប់លោកគ្រូថា៖ «ខ្ញុំចូលចិត្តសមុទ្រ!»



លោកគ្រូនិយាយថា៖ «សមុទ្រនៅឆ្ងាយណាស់។ ប្អូនមិនអាចឃើញវាពីទីនេះបានទេ។»
ខ្ញុំក៏ឆ្លើយថា៖ «តែម៉ែខ្ញុំប្រាប់ថា បើយើងឈរនៅលើអ្វីមួយដែលខ្ពស់ នោះយើងនឹងមើលឃើញបានឆ្ងាយ!»



ខ្ញុំរត់ឡើងលើកំពូលភ្នំ ហើយឈរចំអើត រួចមើលទៅក្រោម។
លោកគ្រូក៏សួរខ្ញុំថា៖«តើប្អូនបានឃើញអ្វីខ្លះ?»



«ខ្ញុំបានឃើញផ្កាសាគូរ៉ា និងសត្វគោកំពុងស៊ីស្មៅ។ តែខ្ញុំមើលមិនឃើញសមុទ្រទេ!»



«មកពីប្អូនឈរមិនទាន់ខ្ពស់គ្រប់គ្រាន់ទេ»
«បើអ៊ីចឹង ខ្ញុំនឹងឈរនៅលើថ្មីដ៏ធំនេះ!»
លោកគ្រូបានជួយលើកខ្ញុំឡើងលើផ្ទាំងថ្ម។



«ឥឡូវនេះ តើប្អូនឃើញសមុទ្រហើយឬនៅ?»
ខ្ញុំក៏ឆ្លើយទាំងក្រៀមក្រំទៅលោកគ្រូ៖ «នៅទេ! ខ្ញុំមើលឃើញតែជម្រាលភ្នំប៉ុណ្ណោះ។ ហើយខ្ញុំមើលឃើញជនជាតិថាយស្លៀកសំពត់ខ្មៅកំពុងលីឈើ និងជនជាតិម៉ុងស្លៀកសំពត់ក្រហមកំពុងកាន់ក្រណាត់យកទៅផ្សារ។»



«ខ្ញុំត្រូវតែឈរឱ្យខ្ពស់ជាងនេះទៀត»។ ខ្ញុំប្រាប់លោកគ្រូថា ខ្ញុំនឹងឡើងទៅលើដើមឈើដែលខ្ពស់បំផុតនៅលើភ្នំ។



លោកគ្រូសួរថា៖ «ឥឡូវនេះ តើប្អូនឃើញអ្វីខ្លះ?»
«ខ្ញុំឃើញទឹកជ្រោះ និងទឹកយ៉ាងថ្លាឈ្វេង»។ ខ្ញុំស្ងាត់មួយភ្លែតពេលខ្ញុំគិត។
បន្ទាប់មក ខ្ញុំប្រាប់គាត់ថា៖ «អ៊ុំ! ភូមិរបស់ខ្ញុំក៏ស្រស់ស្អាតដែរ តែខ្ញុំនៅតែចង់ទៅឃើញសមុទ្រខ្លាំងណាស់ លោកគ្រូ»



«ចុះមកវិញមកមីនា!» លោកគ្រូហៅខ្ញុំ។
«សមុទ្រនៅឆ្ងាយពីទីនេះខ្លាំងណាស់។ ប្អូនត្រូវតែរង់ចាំ
រហូតដល់ប្អូនចេះអក្សរ ហើយជើងរបស់ប្អូនរឹងមាំដូចជាថ្ម ទើប
អាចដើរទៅដល់ទីនោះបាន។ ប៉ុន្តែ ពេលនេះលោកគ្រូមានគំនិត
មួយ»



«នេះនែ! នេះគឺជាសៀវភៅ។ នៅក្នុងសៀវភៅនេះ ប្អូននឹងអាច
មើលឃើញសមុទ្រ ព្រមទាំងវត្ថុថ្មីៗ និងអស្ចារ្យដទៃទៀត។»



ខ្ញុំឃើញពណ៌ខៀវ ខៀវ ខៀវ សុទ្ធតែពណ៌ខៀវ។ «តើនេះគឺជាអ្វីទៅលោកគ្រូ?»

លោកគ្រូឆ្លើយថា៖ «នេះគឺជាផ្ទៃសមុទ្រ។ ទឹកសមុទ្របង្កើតឡើងដោយទឹកទន្លេជាច្រើនរាប់រយ។ ហើយទឹកទន្លេបង្កើតឡើងដោយទឹកស្ទឹងជាច្រើនរាប់រយដែរ។»



«ចុះនេះជាអ្វី?» ខ្ញុំចង្អុលទៅវត្ថុមួយរាងចម្លែក។ «បន្ទះឈើដែលមានក្រណាត់នេះ គឺជាអ្វី?»
«បន្ទះឈើនេះគឺជាទូក ចំណែកឯក្រណាត់នេះគឺជាក្ដោង។ នេះគឺជាទូកនេសាទណាមីនា។ សមុទ្រមានត្រីធំៗប៉ុនផ្ទះឯណោះ!»



ញុំនៅស្ងៀមហើយគិត។ ប្រសិនបើត្រីមានទំហំធំប៉ុនផ្ទះ អ៊ីចឹង សមុទ្រច្បាស់ជាធំខ្លាំងណាស់។ ខ្ញុំញញឹមដាក់លោកគ្រូ។ «ខ្ញុំ គិតថាសមុទ្រនៅឆ្ងាយខ្លាំងណាស់ ខ្ញុំមិនអាចទៅដល់ទេ។ ប៉ុន្តែ វាក៏នៅទីនេះដែរ វានៅក្នុងសៀវភៅដ៏តូចមួយនេះ!»





សទ្ទានុក្រម៖

ថាយ និង ម៉ុង គឺជាឈ្មោះរបស់ជនជាតិភាគតិចពីរក្រុមនៅក្នុង ប្រទេសវៀតណាម។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*May Searches for the Sea*, Author: Đỗ Giáp Nhất. Illustrator: Lê Thị Mai Phương. Published by Room to Read, © Room to Read. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang and Sivngim Nguon